# សិទ្ធិ និងកិច្ចការពាររបស់អ្នកចំពោះប័ណ្ណទារប្រាក់ថ្លៃថែទាំវេជ្ជសាស្ត្រដែលមានតម្លៃខ្ពស់ហួសការរំពឹងទុក

*ពេលអ្នកទទួលសេវាថែទាំវេជ្ជសាស្ត្រក្នុងគ្រាអាសន្ន ឬទទួលការព្យាបាលជំងឺពីអ្នកផ្តល់សេវានៅក្រៅបណ្តាញ នៅក្នុងមន្ទីរពេទ្យ ឬនៅក្នុងមជ្ឈមណ្ឌលវះកាត់ របស់បណ្តាញ គឺអ្នកជាមនុស្សម្នាក់ដែលស្ថិតក្រោមគោលការណ៍អាចតវ៉ាបានចំពោះប័ណ្ណទារប្រាក់ដែលមានតម្លៃខ្ពស់ហួសការរំពឹងទុក ឬប័ណ្ណទារប្រាក់ហួសសមតុល្យ ។*

**អ្វីគឺជា "ប័ណ្ណទារប្រាក់ហួសសមតុល្យ" (ជួនកាលហៅថា "ប័ណ្ណទារប្រាក់តម្លៃខ្ពស់ហួសការរំពឹងទុក")?**

ពេលអ្នកទៅជួបពេទ្យ ឬអ្នកផ្តល់សេវាថែទាំវេជ្ជសាស្ត្រផ្សេងទៀត អ្នកអាចជំពាក់ថ្លៃចំណាយមួយចំនួនដែលត្រូវចេញពីហៅប៉ៅរបស់អ្នក ដូចជាថ្លៃដែលអ្នកត្រូវបង់រួមគ្នាជាមួយសេវាធានារ៉ាប់រងសុខភាព ថ្លៃសហធានារ៉ាប់រងសុខភាព និង/ឬថ្លៃដែលត្រូវកាត់កង ។ អ្នកអាចត្រូវចេញថ្លៃចំណាយផ្សេងទៀត ឬក៏ត្រូវចេញថ្លៃចំណាយសរុបទាំងស្រុងដោយខ្លួនឯង បើអ្នកទៅជួបអ្នកផ្តល់សេវាថែទាំសុខភាព ឬទៅទទួលការព្យាបាលជំងឺនៅក្នុងមណ្ឌលដែលមិនបានស្ថិតក្នុងបណ្តាញផែនការធានារ៉ាប់រងសុខភាពរបស់អ្នក ។

"ក្រៅបណ្តាញ" គឺសំដៅលើអ្នកផ្តល់សេវាថែទាំសុខភាព និងមន្ទីរព្យាបាលជំងឺ ដែលមិនបានចុះកិច្ចសន្យាជាមួយនឹងផែនការធានារ៉ាប់រងសុខភាពរបស់អ្នក ។ អ្នកផ្តល់សេវាថែទាំសុខភាពក្រៅបណ្តាញ មានសិទ្ធិផ្ញើប័ណ្ណទារប្រាក់ទៅអ្នក នូវចំនួនទឹកប្រាក់ដែលផែនការធានារ៉ាប់រងសុខភាពរបស់អ្នកយល់ព្រមបង់ និងប័ណ្ណទារប្រាក់បង្ហាញថ្លៃសេវាសរុបរបស់អ្នក ។ ត្រង់នេះគេហៅថា "**ប័ណ្ណទារប្រាក់ហួសសមតុល្យ**" ។ ទឹកប្រាក់នេះ គឺមានបរិមាណច្រើនជាងតម្លៃរបស់អ្នកផ្តល់សេវានៅក្នុងបណ្តាញ ចំពោះសេវាដែលដូចគ្នា ហើយអាចមិនត្រូវគិតចូលក្នុងដែនកំណត់នៃទឹកប្រាក់ដែលត្រូវចេញពីហោប៉ៅរបស់អ្នកប្រចាំឆ្នាំ ។

SUMMIT
ORTHOPEDICS

"ប័ណ្ណទារប្រាក់មានតម្លៃហួសការរំពឹងទុក" គឺជាប័ណ្ណទារប្រាក់មានតម្លៃហួសសមតុល្យ ដែលខុសការរំពឹងទុក ។ ស្ថានភាពនេះ អាចកើតឡើង នៅពេលដែលអ្នកមិនអាចគ្រប់គ្រងបានថាតើនរណាខ្លះដែលត្រូវពាក់ព័ន្ធក្នុងការព្យាបាលជំងឺរបស់អ្នក ដូចជាពេលអ្នកស្ថិតក្នុងស្ថានភាពអាសន្ន ឬពេលអ្នកមកជួបពេទ្យនៅមណ្ឌលរបស់អ្នកផ្តល់សេវាថែទាំសុខភាពនៅក្នុងបណ្តាញ តែខុសពីការគិតទុក គឺអ្នកត្រូវទទួលការព្យាបាលពីអ្នកផ្តល់សេវានៅក្រៅបណ្តាញ ។

**អ្នកជាមនុស្សស្ថិតក្រោមកិច្ចការពារពីប័ណ្ណទារប្រាក់ហួសសមតុល្យ ក្នុងស្ថានភាព ៖**

**សេវាថែទាំសុខភាពក្នុងគ្រាអាសន្ន**

បើជំងឺរបស់អ្នក ស្ថិតក្នុងស្ថានភាពអាសន្ន ហើយអ្នកទទួលបានសេវាថែទាំក្នុងគ្រាអាសន្ន ពីអ្នកផ្តល់សេវា ឬពីមណ្ឌលថែទាំនៅក្រៅបណ្តាញ អ្វីដែលអ្នកផ្តល់សេវាថែទាំសុខភាព ឬមន្ទីរថែទាំសុខភាព អាចធ្វើគឺផ្ញើប័ណ្ណទារប្រាក់ឲ្យអ្នក នូវបរិមាណទឹកប្រាក់ដែលអ្នកត្រូវចូលរួមចំណាយទៅតាមផែនការធានារ៉ាប់រងសុខភាពក្នុងបណ្តាញរបស់អ្នក (ដូចជា ថ្លៃចំណាយរួមគ្នា ឬថ្លៃសហធានារ៉ាប់រងសុខភាព) ។ គេមិនអាចផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យ ឲ្យអ្នក ចំពោះសេវាថែទាំជំងឺក្នុងគ្រអាសន្នទាំងអស់នេះ ដល់អ្នកបានឡើយ ។ ត្រង់នេះ គឺរួមបញ្ចូលនូវសេវានានា ដែលអ្នកបានទទួល ក្រោយពេលស្ថានភាពជំងឺអ្នកស្ថិតក្នុងសភាពនឹងហ្ន៎ ប្រសិនបើអ្នកមិនបានផ្តល់សេចក្តីយល់ព្រមជាលាយល័ក្ខណ៍អក្សរ និងបោះបង់កិច្ចការពាររបស់អ្នក មិនឲ្យគេផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យ ចំពោះថ្លៃសេវាថែទាំទាំងអស់នេះ ក្រោយពេលស្ថានភាពជំងឺរបស់អ្នកស្ថិតក្នុងសភាពធូរស្រាល ។

SUMMIT
ORTHOPEDICS

**សេវាថែទាំជាក់លាក់ ពីមន្ទីរពេទ្យ ឬមណ្ឌលវះកាត់ក្នុងបណ្តាញ**

ពេលអ្នកបានទទួលសេវាថែទាំសុខភាពពីមន្ទីរពេទ្យ ឬមណ្ឌលវះកាត់ក្នុងបណ្តាញ អ្នកផ្តល់សេវាមួយចំនួនអាចជាអ្នកស្ថិតនៅក្រៅបណ្តាញ ។ ស្ថិតក្នុងស្ថានភាពនេះ អ្វីដែលអ្នកផ្តល់សេវាទាំងអស់នោះអាចធ្វើគឺ ផ្ញើប័ណ្ណទារប្រាក់ដល់អ្នក នូវចំនួនទឹកប្រាក់ដែលអ្នកត្រូវចូលរួមបង់ ទៅតាមផែនការធានារ៉ាប់រងសុខភាពក្នុងបណ្តាញរបស់អ្នក ។ កិច្ចការនេះ ក៏អាចអនុវត្តបានចំពោះការថែទាំវេជ្ជសាស្ត្រក្នុងគ្រាអាសន្ន ការធ្វើរោគសាស្ត្រ ការឆ្លុះវិទ្យុសាស្ត្រ ការពិនិត្យដោយមន្ទីរពិសោធន៍ ការថែទាំទារកទើបកើត ជំនួយការវះកាត់ សេវាព្យាបាលនៅមន្ទីរពេទ្យ ឬ សេវាព្យាបាលជំងឺធ្ងន់ធ្ងរ ។ អ្នកផ្តល់សេវាទាំងអស់នេះ មិនអាចផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យ ឲ្យអ្នក ហើយក៏មិនអាចសុំឲ្យអ្នកបោះបង់កិច្ចការពាររបស់អ្នក មិនឲ្យពួកគេផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យ ឲ្យអ្នកបានឡើយ ។

បើអ្នកទទួលបានសេវាថែទាំសុខភាពផ្សេងទៀត ពីមន្ទីរថែទាំក្នុងបណ្តាញទាំងអស់នេះ ក៏អ្នកផ្តល់សេវានៅក្រៅបណ្តាញ មិនអាចផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យ ឲ្យអ្នកបានដែរ បើអ្នកមិនបានផ្តល់សេចក្តីយល់ព្រមជាលាយល័ក្ខណ៍អក្សរ និងបោះបង់កិច្ចការពាររបស់អ្នកទេនោះ ។

**មិនដែលមាននរណាតម្រូវឲ្យអ្នក បោះបង់កិច្ចការពាររបស់អ្នក ពីការផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យឡើយ ។ ក្នុងនេះផងដែរ គេក៏មិនតម្រូវឲ្យអ្នកត្រូវទទួលសេវាថែទាំសុខភាពពីអ្នកផ្តល់សេវានៅក្រៅបណ្តាញដែរ ។ អ្នកអាចជ្រើសយកអ្នកផ្តល់សេវាថែទាំសុខភាព ឬមន្ទីរព្យាបាល ដែលស្ថិតក្នុងបណ្តាញនៃផែនការធានារ៉ាប់រងសុខភាពរបស់អ្នក ។**

**នៅពេលដែលប័ណ្ណទារប្រាក់ហួសសមតុល្យ មិនត្រូវអនុញ្ញាតឲ្យប្រើ អ្នកក៏ត្រូវទទួលបានកិច្ចការពារដូចខាងក្រោមផងដែរ ៖**

» អ្នកត្រូវទទួលខុសត្រូវចំពោះតែការបង់ប្រាក់ដែលជាចំណែករបស់អ្នកប៉ុណ្ណោះ (ដូចជាថ្លៃចំណាយរួមគ្នា ថ្លៃ

SUMMIT ORTHOPEDICS

សហចំណាយ និងប្រាក់ដែលអាចកាត់កងបាន ដែលអ្នកត្រូវបង់ ដល់អ្នកផ្ដល់សេវា ឬមន្ទីរថែទាំព្យាបាល ក្នុងបណ្ដាញ) ។ ផែនការធានារ៉ាប់រងសុខភាពរបស់អ្នក នឹងបង់ប្រាក់ដល់អ្នកផ្ដល់សេវា និងមន្ទីរថែទាំព្យាបាលនៅក្រៅបណ្ដាញ ដោយផ្ទាល់ ។

- ជាទូទៅ ផែនការធានារ៉ាប់រងសុខភាពរបស់អ្នកត្រូវតែ ៖
  - ផ្ដល់ការធានារ៉ាប់រងចំពោះថ្លៃសេវាថែទាំក្នុងគ្រាអាសន្ន ដោយមិនបាច់តម្រូវឲ្យអ្នក ទទួលបានការយល់ព្រម ឲ្យទទួលសេវាកម្មនេះ ជាមុនឡើយ (ការអនុញ្ញាតជាមុន) ។
  - ផ្ដល់ការធានារ៉ាប់រងចំពោះថ្លៃសេវាថែទាំក្នុងគ្រាអាសន្ន ដែលផ្ដល់ជូនដោយអ្នកផ្ដល់សេវានៅក្រៅបណ្ដាញ
  - ដោយសំអាងលើប្រាក់ដែលអ្នកជំពាក់ចំពោះអ្នកផ្ដល់សេវា ឬមន្ទីរព្យាបាល (ថ្លៃចូលរួមការចំណាយ) លើទឹកប្រាក់ដែលខ្លួនត្រូវបង់ ដល់អ្នកផ្ដល់សេវា ឬមន្ទីរព្យាបាលក្នុងបណ្ដាញ ហើយបង្ហាញទឹកប្រាក់នេះក្នុងឯកសារពន្យល់អំពីអត្ថប្រយោជន៍ធានារ៉ាប់រងសុខភាពរបស់អ្នក ។
  - រាប់បញ្ចូលទឹកប្រាក់ទាំងអស់ដែលអ្នកបង់សម្រាប់ថ្លៃសេវាថែទាំក្នុងស្ថានភាពអាសន្ន ឬទឹកប្រាក់ដែលអ្នកបានបង់ចំពោះថ្លៃសេវាថែទាំសុខភាពក្រៅបណ្ដាញ ទៅក្នុងដែនកំណត់នៃទឹកប្រាក់ដែលអាចកាត់កងបាន និងទឹកប្រាក់ចេញពីហោប៉ៅរបស់អ្នក ។

បើអ្នកជឿថា គេផ្ញើប័ណ្ណទារប្រាក់ហួសសមតុល្យ ឲ្យអ្នក, អ្នកអាចទាក់ទងការិយាល័យធានារ៉ាប់រងសុខភាពរបស់អ្នក តាមទូរស័ព្ទលេខ **(651) 968-5050** ។ សូមចូលទៅកាន់ www.cms.gov/nosurprises ដើម្បីមើលព័ត៌មានបន្ថែម អំពីសិទ្ធិរបស់អ្នកក្រោមច្បាប់សហព័ន្ធ ។

ក្នុងនេះផងដែរ អ្នកក៏អាចចូលទៅកាន់ www.ag.state.mn.us/consumer/health/default.asp ដើម្បីអានព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកក្រោមច្បាប់របស់រដ្ឋមីណេសូតា ។

SUMMIT ORTHOPEDICS